# សិក្ខាសាលាថ្នាក់ជាតិស្តីពី
# ផលិតកម្ម និងការប្រើប្រាស់ដំណាំដំឡូងមីប្រកបដោយនិរន្តរភាពដើម្បីកាត់បន្ថយភាពក្រីក្រ
# នៅជនបទ ក្នុងប្រទេសកម្ពុជា

ដំឡូងមីជាដំណាំចំការដ៏សំខាន់នៅកម្ពុជា។ នាឆ្នាំថ្មីៗកន្លងមក ដំណាំដំឡូងមីកាន់តែមានសារសំខាន់ខ្លាំងឡើងដោយសារតម្រូវការកើនឡើងយ៉ាងខ្លាំងពីអ្នកកែច្នៃដើម្បីផ្គត់ផ្គង់ដល់ទីផ្សារក្នុងស្រុកនិងក្រៅស្រុក។ ក្នុងឆ្នាំ២០១១ ជាការឆ្លើយតបទៅនឹងការកើនឡើងនូវតម្លៃដំឡូងមី នាឆ្នាំកន្លងមក ផ្ទៃដីដាំដុះដំឡូងមីបានកើនឡើងជិតទ្វេហើយមានការប្រកួតប្រជែងជាមួយដំណាំពោតដែល ជាដំណាំចម្ការសំខាន់បំផុតនាកន្លងមក ដោយផ្អែកលើផ្ទៃដីដាំដុះ និងតម្លៃសម្រាប់អ្នកដាំដុះ។

ថ្វីត្បិតតែដំឡូងមីផ្តល់នូវប្រាក់ចំណូលច្រើន កាលានុវត្តភាពជីវភាពគ្រួសារ និងប្រាក់ចំណេញដល់កសិករខ្នាតតូចក្នុងប្រទេសកម្ពុជាក៏ដោយ ក៏នៅតែជាក្តីកង្វល់អំពីការប្រែប្រួលតម្លៃ ស្ថេរភាពទីផ្សារ ទុព្វលភាពដី ការសម្អាតព្រៃឈើខុសច្បាប់ និងការគ្រប់គ្រងផលិតកម្មដំណាំដំឡូងមីប្រកបដោយនិរន្តរភាព ដើម្បីផ្តល់ភាពចំណេញដល់កសិករខ្នាតតូច និងវិស័យឧស្សាហកម្មក្នុងប្រទេសកម្ពុជា។

ដោយមានការឧបត្ថម្ភថវិកាពីមូលនិធិជប៉ុននិងមូលនិធិអាយហ្វាត វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា(កាឌី)សហការជាមួយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់កសិកម្មតំបន់ត្រូពិច(ស៊ីអាត) បានរៀបចំសិក្ខាសាលាថ្នាក់ជាតិរយៈពេល២ថ្ងៃ ដោយមានសិក្ខាកាមចូលរួមចំនួន២៣០នាក់ រួមមានអ្នកនយោបាយ និងអ្នកពាក់ព័ន្ធវិស័យដំឡូងមីជាច្រើន។ សិក្ខាសាលានេះបានប្រកាសបើកជាផ្លូវការក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សិក្ខាកាមបានឯកភាពគ្នាជាគោលការណ៍ថា ដំឡូងមីនៅតែជាដំណាំចម្ការដ៏សំខាន់ ប៉ុន្តែផលិតកម្មរបស់វាចាំបាច់ត្រូវគ្រប់គ្រងឲ្យបានល្អដើម្បីធានានូវនិរន្តរភាពនិងថែរក្សានូវបរិស្ថាន។ សិក្ខាសាលានេះ ទទួលបានលទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១.អភិវឌ្ឍនច្បាប់ផលិតកម្មដំឡូងមីជាចាំបាច់ ដើម្បីឲ្យមានផែនការច្បាស់លាស់ក្នុងការទប់ស្កាត់ និងការពារពីការកាប់ព្រៃឈើខុសច្បាប់ ធានាទីផ្សារ និងតម្លៃទីផ្សារដល់កសិករក្រីក្រ កំណត់ផ្ទៃដីផលិតកម្មទាក់ទងនឹងតម្រូវការទីផ្សារ និងការភ្ជាប់កសិករទៅនឹងតម្លៃចង្វាក់ផលិតកម្មដំឡូងមី។

២.ជម្រុញការស្រាវជ្រាវដើម្បីអភិវឌ្ឍនូវបច្ចេកទេសថ្មីៗប្រកបដោយនិរន្តរភាព ដោយផ្តោតជាសំខាន់លើ (ក)ពូជអាយុលាលខ្លី និងសមាភាពម្សៅខ្ពស់ (ខ) ការគ្រប់គ្រងជីវជាតិដី-ដំណាំឲ្យមាននិរន្តរភាពយូរ

អង្វែង (គ)បច្ចេកទេសសមស្របមុននិងក្រោយពេលប្រមូលផល (ឃ) ការគ្រប់គ្រងសមាសភាពចង្រៃ និងជំងឺ។

៣.ផ្សៀងផ្ទាត់អត្ថបទ និងបោះពុម្ព បច្ចេកទេសមានស្រាប់ និងចែកចាយឲ្យបានទូលំទូលាយដល់ដៃកសិករតាមរយៈ ការធ្វើស្រែបង្ហាញ និងមធ្យោបាយដទៃៗទៀត។

៤.ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គភាពស្រាវជ្រាវជាតិនិងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុកនានាដើម្បីធ្វើឲ្យប្រសើរឡើងនូវការស្រាវជ្រាវសម្រាប់ផលិតកម្ម និងការប្រើប្រាស់ដំណាំដំឡូងមីប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។

